# វចារណកថា

ដោយ មីស្ហែល ឫទ្ធី អង់តែល្ម

អស់រយៈពេលពីរឆ្នាំមកហើយ ដែលគម្រោងការបង្កើតមជ្ឈមណ្ឌលខេមរសិក្សាបានចាប់ផ្ដើមមានដំណើរការឡើង ដោយមាននិស្សិត ៤ នាក់ ដែលបានជួបគ្នានៅប្រទេសអង់គ្លេស បានមកប្រទេសខ្មែរ ។ ទោះជាមានការលំបាក ដែលអស់ការបង្កើតថ្មី ។ តែងតែជួបប្រទះក៏ដោយ ក៏យើងតែងតែមានសំណាងចាប់ពីពេលដំបូងរហូតមក ដោយសារបានជួបប្រទះមនុស្សច្រើននាក់ ដែលបានដាក់សេចក្ដីទុកចិត្ត និងសេចក្ដីសង្ឃឹមទៅលើផលប្រយោជន៏របស់មជ្ឈមណ្ឌលយើង ហើយអ្នកទាំងនោះ បានផ្ដល់មកនូវការជួយជ្រោមជ្រែងរបស់គេ ដោយសុទ្ធចិត្ត ។ ហេតុនេះហើយបានជាការសុំច្បាប់អនុញ្ញាតពីក្រសួងរាជការនានា បានសម្រេចទៅដូចបំណង ។ ចៃដន្យ ក៏បាននាំខ្មែរម្នាក់ ជាអ្នកសៀមរាប ធ្លាប់រៀននៅសាលាវត្តដំណាក់ មករ៉ាយរ៉ាប់ប្រាប់យើងខ្ញុំ អំពីសេចក្ដីព្រួយចិត្តរបស់គាត់ ព្រោះតែសភាពទ្រុឌទ្រោមនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងវត្តដំណាក់ ។ ចាប់ពីពេលនោះមក សហការដ៏សក្ដិសិទ្ធ ក៏បានចាប់ផ្ដើមមានឡើង ជាមួយនឹងព្រះសង្ឃ លោកអាចារ្យ និងពួកឧបាសកឧបាសិកា ។

ក្រុមធ្វើការដំបូង បានរីកធំឡើងបន្តិចម្ដង ។ ។ សាស្ត្រាចារ្យអ្នកស្រាវជ្រាវ និស្សិតដែលជាទីសង្ឃឹមសម្រាប់អនាគត ក៏ចេះតែមកដល់មជ្ឈមណ្ឌលជារឿយ ។ ។ ក្នុងចំណោមពួកយើង អ្នកខ្លះត្រូវទៅបំពេញការងារផ្សេង ។ ទៀត នៅកន្លែងដទៃ តែទោះជាយ៉ាងណា ក៏យើងនៅតែរក្សាទុកទំនាក់ទំនង និងការធ្វើដំណើរទៅមក មិនឈប់មិនឈរ ជានិច្ច ។

ក្នុងកំឡុងពេលពីរឆ្នាំក្រោយមក សកម្មភាពជាច្រើនបានទទួលនូវផលសម្រេច តែក៏នៅសល់សកម្មភាពមួយចំនួនធំទៀតដែលត្រូវធ្វើ ដូចពាក្យចាស់លោកថា តក់ ។ ពេញបំពង់ ឆុង ។ កំពប់អស់ ។ ព្រឹត្តិប័ត្រ *សិក្សាចក្រ* ក៏ដូច្នេះដែរ ។ នៅពេលដំបូង ព្រឹត្តិប័ត្រយើងមាននាទីរាយការណ៏អំពីសកម្មភាពរបស់មជ្ឈមណ្ឌលយើង និងស្ថាប័នទាំងឡាយ ដែលគ្រប់គ្រងមជ្ឈមណ្ឌលយើង ថ្វីត្បិតតែយើងយល់ព្រមបោះពុម្ពផ្សាយនូវអត្ថបទសិក្សា ស្រាវជ្រាវចំនួនតិចក៏ដោយ ។ តែដោយហេតុថា *សិក្សាចក្រ* បានទទួលជោគជ័យដែលយើងពុំបានប្រុងទុកមុន បានជាយើងសម្រេចចិត្តកែប្រែនូវគោលជំហរនៃការបោះពុម្ពផ្សាយរបស់យើង ។

ដោយសារមានអត្ថបទជាភាសាខ្មែរ បារាំង និងអង់គ្លេសចេះតែហូរចូលមក ក្រុមបោះពុម្ពផ្សាយរបស់ *សិក្សាចក្រ* សម្រេចចិត្តថា ត្រូវឲ្យអត្ថបទសិក្សាស្រាវជ្រាវ ទៅជាភាគសំខាន់ ដូចដែលអស់លោកអ្នកបានសង្កេតឃើញរួចមកហើយ ។

នៅក្នុងលេខនេះ មានអត្ថបទស្ដីអំពីស្ថាបត្យកម្មក្នុងស្រុក ១ អត្ថបទស្ដីអំពីការពិចារណាថ្មីនូវកាលបរិច្ឆេទប្រវត្តិសាស្ត្រ ក្នុងសតវត្សរ៏ទីប្រាំបួន ១ អត្ថបទ សង្ខេបសារណាបញ្ចប់ថ្នាក់បរិញ្ញប័ត្រស្ដីពីកំណើតរដ្ឋបាលឃុំខ្មែរ ១ (ដោយចៃដន្យ អត្ថបទនេះត្រូវពេលនឹងយុទ្ធនាការ និងការជ្រើសរើសបោះឆ្នោត ថ្នាក់ឃុំ–សង្កាត់) អត្ថបទស្ដីអំពីបញ្ហាដែលពាក់ព័ន្ធនឹងគ្រូបង្រៀននៅតាមជនបទ ១ សេចក្ដីវិភាគចំណុចវេយ្យាករណ៏ខ្មែរខ្លះ ។ ១ ការស្រាវជ្រាវអំពីទំនាក់ទំនងរវាងប្រទេសកទិាដក និងប្រទេសកម្ពុជា នាសម័យបុរាណ ១ ។ល។ អ្នកដែលបានចូលរួមសរសេរអត្ថបទទាំងឡាយ នៅក្នុងលេខនេះមានទាំងអ្នកស្រាវជ្រាវដ៏ល្បីឈ្មោះ និស្សិត អ្នកធ្វើការនៅនឹងកន្លែង និងជនសាមញ្ញធម្មតាផងដែរ ។ ម្នាក់ ។ សុទ្ធតែមានតម្រិះនិងចំណេះដឹងមកចែកដល់យើងគ្រប់គ្នា ។

យើងខ្ញុំសូមពឹងអស់លោកអ្នកយ៉ាងជឿជាក់ ដើម្បីឲ្យគំនិតស្វាហាប់ និងប្រកបដោយវីរិយៈយ៉ាងនេះក្នុងខេមរវិទ្យា នៅតែគង់វង់ស្ថិតស្ថេរ ។

ដូចអស់លោកអ្នកបានសង្កេតឃើញស្រាប់ហើយក្នុងលេខមុន ។ មានអត្ថបទជាច្រើន ដែលពុំអាចចៀសវាងកុំឲ្យមានកំហុសខាងការរៀបអក្សរ កុំឲ្យមានការរៀបពុម្ពច្រឡំ និងកុំឲ្យសេចក្ដីបកប្រែមានការខុសឆ្គងបាន ។ គុណវិបត្តិអស់នេះ មកពីយើងមានការងារធ្ងន់ធ្ងរពេក ។ ម្យ៉ាងទៀត យើងប្រើ ៣ ភាសា តែគ្នាយើងភាគតិចណាស់ដែលចេះទាំង ៣ ភាសា នេះ ។ គុណវិបត្តិនេះក៏មកពីកំណត់ពេលតឹងរ៉ឹង និង បញ្ហាខាងប្រព័ន្ធកុំព្យូទ័រ (ដូចជាប្រព័ន្ធកុំព្យូទ័រផ្សេងគ្នា មិនសមស្របគ្នា បញ្ហាខាងការផ្ញើឯកសារតាមប្រៃសណីយ៏ និងតាមអ៊ិនធឺរណែត ព្រោះថា ក្រុមយើងរាត់រាយ ខ្ចាត់ខ្ចាយតាមនានាប្រទេស) ។ គុណវិបត្តិនេះ នៅតែមានទោះជាមានការខិតខំប្រឹងប្រែងពុំចេះចប់ និងការចាប់ចិត្តឲ្យចង់ធ្វើល្អឥតខ្ចោះក៏ដោយ ។ យើងសូមដឹងគុណលោកអ្នក បើសិនអស់លោកអ្នកមេត្តាបង្ហាញនូវកំហុសរបស់យើង ហើយយើងខ្ញុំសូមអភ័យទោសអំពីភាពមិនទាន់ល្អសព្វគ្រប់យ៉ាងនេះ ។

យើងខំប្រឹងដើម្បីឲ្យសភាពនៃព្រឹត្តិប័ត្រនេះល្អឡើង ហើយយើងសង្ឃឹមថា លោកអ្នកនឹងចូលចិត្តអក្សរពុម្ព ដែលមានប្រើនៅក្នុងលេខនេះ ជាពិសេសអក្សរខ្មែរដែលកាន់តែល្អឡើង និងកាន់តែស្រួលអានដោយសារការងារដ៏ប្រសើររបស់លោក ដាញ់ ហុង ។

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអស់លោកអ្នកដែលជួយឲ្យ *សិក្សាចក្រ* ប្រកបដោយជោគជ័យ ៕